238	MEDIVET CO.LTD	Co 3483 97P	No 19E1, St 336, Sangkat Veal Vong, Khan 7 Makara, City Phnom Penh

2??	MEGA MAX INTERNATIONAL LTD	Co 0456 93E	No 17?E St 169 Sangkat Veal Vong Khan 7 Makara, City Phnom Penh
?4?	MEKONG IMPORT & EXPOR COMPANY LTD	Co ?56 96P	No 33Eo St ?1 Sangkat Boeng Pr??t Khan 7 Makara, City Phnom Penh
24?	MEKONG INTERNATIONAL LTD	Co 0?0? 9?P	No 6, St 184, Sangkat Phsar Thme 3 Khan Daun Penh City Phnom Penh
242	MEKONG TELECOM MOBILE INT	INV 0233 96E	No ?? E?F1E2, St 110 Sangkat Wat Phnom Khan Daun Penh City Phnom Penh
243	MENG ANG CO LTD	Co 342? 9?P	No 4Eo St 164, Sangkat Orussei 3, Khan 7 Makara City Phnom Penh
244	MESRA HOLDINGS CAMBODIA LTD	Co ?15 94P	No 11, St 1?6, Sangkat Veal Vong Khan 7 Makara, City Phnom Penh
245	MING PHAT TRADING CO LTD	Co 2006 96P	No 203Eo, St 274, Sangkat Veal Vong Khan 7 Makara City Phnom Penh
246	MITTAPHEAP AGRICULTURE DEVELOPMENT LTD	Co 126? 9?P	No ?9BCE2 St Kampuchea Krom(128), Sangkat Monorom, Khan 7 Makara City Phnom Penh
247	MOHASAKO EXPORT IMPORT CO LTD	Co 1536 95P	No 201EoE? St Monivong Sangkat Monorom, Khan 7 Makara City Phnom Penh
248	MOI TRADING CO LTD	Co 0 ?? 93P	No 68Eo, St 138, Sangkat Veal Vong, Khan 7 Makara, City Phnom Penh
249	MULTI-TECH IMPORT EXPORT CO LTD	Co 4? 8 9?P	No ?B St 2006 200? Sangkat Kakap Khan Dang kor City Phnom Penh
25?	NATION CONSTRUCTION CAMPANY IMPORT EXPORT LIMITED	Co 0758 9?P	No ?03 E? St ?34 Sangkat Mittapheap Khan 7 Makara, City Phnom Penh
25?	NING FENG NEON LIGHT ADERTISING CO.,LTD	Co 3?5? 98P	No ?78BEo, St 109, Sangkat Orussei 4 Khan 7 Makara City Phnom Penh
252	NING LIAN INTERNATIONAL ECONOMIC TECHNOLOGY AND CONSULTING CO LTD	Co 01?? 96E	No 49?Eo, St 128, Sangkat Mittapheap Khan 7 Makara City Phnom Penh
253	NOLED IMPORT EXPORT CO.,LTD	Co 15(4 9?P	No ?5 ROOM 10, St 2?1, Sangkat Veal Vong, Khan 7 Makara City Phnom Penh
254	OCEAN DRAGON TRADING CO.,LTD	Co 10 8 94P	No ?4? E2, St 169, Sangkat Veal Vong Khan 7 Makara, City Phnom Penh
255	ONG KIAT ENTERPRISE CO.,LTD	Co 1235 9?P	No 36 Eoz, St 164, Sangkat Orussei 3, Khan 7 Makara, City Phnom Penh
256	OPM PERFECT CONSTRUCTION AND DEVELOPMENT Co.,Ltd	Co 308? 97P	No 5E1, St 139, Sangkat Veal Vong Khan 7 Makara City Phnom Penh
257	ORIENTAL TRADE DEVELOPMENT NETWORK LTD	Co 35?? 97P	No 9?AEoF1 St 214, Sangkat Boeng Proluet, Khan 7 Makara, City Phnom Penh
258	PAN EURO ASIAN (JEWELRY) CO.,LTD	Co 2846 97P	No 63Eo, St ?09, Sangkat Veal Vong Khan 7 Makara, City Phnom Penh

7

259	PAO LUNG DEVELOPMENT IMPORT EXPORT CO., LTD	Co 2885/97P	No 9.BE [illegible] St 274 Sangkat Boeng Prolit Khan 7 Makara City Phnom Penh
260	PARK AVENUE CO., LTD	Co 1032/94P	No 18 [illegible] St Monivong Sangkat Monorom Khan 7 Makara City Phnom Penh
261	PARKALINE ENTERPRISE P.E LTD	Co 1422/95P	No 137A St 128 Sangkat Mittapheap Khan 7 Makara City Phnom Penh
262	PHNOM PENH EXPRESS IMPORT EXPORT & TRANSPORT	Co 0196/93P	No 10E [illegible] St 164 Sangkat Mittapheap, Khan 7 Makara City Phnom Penh
263	POLITIAN IMPORT EXPORT CO., LTD	Co 1462/95P	No 14BEo St 163, Sangkat Veal Vong, Khan 7 Makara City Phnom Penh
264	POLYCON CAMBODIA CO.,LTD	Co 0611/94P	No 59AE [illegible] St 113+242 Sangkat Boeng Prolit, Khan 7 Makara City Phnom Penh
265	PRACH HENG IMPORT EXPORT CO LTD	Co 1722/95P	No 10CE [illegible] St 111, Sangkat Orussei 1 Khan 7 Makara, City Phnom Penh
266	PRAMOL SAMBATH IMPORT EXPORT & CONSTRUCTION CO LTD	Co 3564/97P	No 172AE St 215 Sangkat Veal Vong Khan 7 Makara City Phnom Penh
267	PRAYOON TAING [illegible] P PROSPER INVESTMENT AND DEVELOPMENT CO LTD	Co 0004/93E	No 333Eo St 128 Sangkat Mittapheap Khan 7 Makara City Phnom Penh
268	PRETSONS (CAMBODIA) LIMITED	Co 1247/95P	No 15 St 166 Sangkat Veal Vong Khan 7 Makara City Phnom Penh
269	PROFOUND AXES CO., LTD	Co 1325/95P	No 34 E1 St 217 Sangkat Orussei 3, Khan 7 Makara City Phnom Penh
270	PROPEL CORPORATION CAMBODIA CO LTD	Co 0588/94P	No 31E [illegible] St [illegible] Sangkat Boeng Prolit Khan 7 Makara City Phnom Penh
271	RATANAK SEA DEVELOPMENT AGRICULTURE CO LTD	Co 2273/96P	No 135EoZ St 93, Sangkat Monorom, Khan 7 Makara City Phnom Penh
272	RATTANAKIRI CORPORATION CO LTD	Co 1020/94P	No 10E2 St 217, Sangkat Orussei 4, Khan 7 Makara City Phnom Penh
273	R S Co Ltd	Co 5065/00P	No176E1 St 130,Sangkat Phsachas,Khan Dounpenh Phnompenh City
274	RISE RICH IMPORT EXPORT CO LTD	Co 2817/97P	No 268Eo St 128 Sangkat Mittapheap Khan 7 Makara City Phnom Penh
275	ROCCO IMPORT EXPORT CO.,LTD	Co 0780/94P	No 190EoZ St 107, Sangkat Orussei 4 Khan 7 Makara, City Phnom Penh
276	ROYAL ARCHITECHTURE ENGINEERING GROUP CO LTD (ROYAL A E CONSTRUCTION)	Co 4399/99P	No 257Eo, St 274, Sangkat Veal Vong, Khan 7 Makara, City Phnom Penh
277	ROYAL CAMBODIA TRUSTS & INVESMENTS S A	Co 1316/95P	No 437, St Monivong, Sangkat Boeng Prolit, Khan 7 Makara, City Phnom Penh
278	S R CORPORATION Co.,Ltd	Co 4730/99P	No 107-113, St Monivong, Sangkat Monorom, Khan 7 Makara, City Phnom Penh

[illegible]	SAGE INVESTING & DEVELOPING GROUP CO.,LTD	Co [illegible]39 95P	No 7Eo St 169 Sangkat Mittapheap Khan 7 Makara City Phnom Penh
[illegible]	SAHAKMIT INVERSTMENT GROUP CO.,LTD	Co 122[illegible] 95P	No 44 St [illegible] Sangkat Veal Vong Khan 7 Makara City Phnom Penh
[illegible]	SAMAKI PEANICH IMPORT EXPORT & CONSTRUCTION CO.,LTD	Co 0[illegible]6 94P	No 44 St 141 Sangkat Veal Vong Khan 7 Makara City Phnom Penh
[illegible]	SAMNANG BOPEA IMPORT EXPORT LTD	Co 3066 97P	No 52E1 St [illegible]1 Sangkat Orussei 1 Khan 7 Makara City Phnom Penh
283	SAN MAC CAMBODIA EXPORT IMPORT CO.,LTD	Co 04[illegible]1 93P	No 15B St [illegible]65 Sangkat Boeng Proluit, Khan 7 Makara City Phnom Penh
284	SAND T Co Ltd	Co 46[illegible]3 99P	No 60 B St 141 Sangkat Veal Vong, Khan 7 Makara City Phnom Penh
285	SAR CHANDARA CONSTRUCTION & IMPORT EXPORT CO.,LTD	Co 3345 97P	No 208E1 St 217 Sangkat Orussei 3, Khan 7 Makara City Phnom Penh
286	SARIMEXCO	Co 0369 93P	No 258, St 107 Sangkat Boeng Proluit Khan 7 Makara City Phnom Penh
287	SEASIA IMPORT EXPORT & PHARMACEUTICALS PRODUCTS CO.,LTD	Co 0741 94P	No 103Eo St Monivong Sangkat Monorom Khan 7 Makara City Phnom Penh
288	SEN LOGISTICS (CAMBODIA) PRIVATE LIMITED	Co 3536 97P	No 5 St 138 Sangkat Veal Vong Khan 7 Makara City Phnom Penh
289	SENG MEAN EHNG CO.,LTD	Co 41[illegible]9 98P	No 319, St Mao Tse Toung, Sangkat Phsardepo 1 Khan 7 Makara City Phnom Penh
[illegible]	SETHIS OVERSEAS COMBIND CO.,LTD	Co 4070 98P	No 103GEo St [illegible] Sangkat Orussei 3 Khan 7 Makara City Phnom Penh
[illegible]	SHARITHORN IMPORT EXPORT CO.,LTD	Co [illegible]32 94P	No 97Eo St 1[illegible]7 Sangkat Orussei 4 Khan 7 Makara City Phnom Penh
292	SIEK HENG AGREXIM INVESTMENT LTD	Co 1272 95P	No 6AE1, St 111, Sangkat Boeng Proluit Khan 7 Makara, City Phnom Penh
293	SIN LEE ENTERPRISES IMPORT EXPORT CO.,LTD	Co 1206 95P	No 248DEo St 107 Sangkat Boeng Proluit, Khan 7 Makara City Phnom Penh
294	SIN NGUON INVESTMENT GROUP CO.,LTD	Co 4729 99P	No 333AEo, St 109 Sangkat Orussei 4 Khan 7 Makara, City Phnom Penh
295	SIN THAI KAMPOT AGRICULTURE CO.,LTD	INV 0206 96P	No 253E1, St Kampuchea Krom, Sangkat Mittapheap, Khan 7 Makara, City Phnom Penh
296	SINA IMPORT EXPORT SINGAMEX CO.,LTD	Co 0857 94P	No 54E1 Z, St 166, Sangkat Olympic Khan 7 Makara City Phnom Penh
297	SINFA CO.,LTD	Co 4769 99P	No [illegible]GEo, St [illegible]66, Sangkat Orussei 1 Khan 7 Makara City Phnom Penh
298	SING HUO LEAN CAMBODIA INTERNATIONAL IMPORT EXPORT & CONSTRUCTION CO.,LTD	Co 2997 97P	No [illegible]46 AB, St 2[illegible]5 Sangkat Veal Vong, Khan 7 Makara, City Phnom Penh

29[illegible]	SING KOUNG IMPORT EXPORT CO LTD	Co 2918 97P	No 93-195 Eo, St 128, Sangkat Mittapheap, Khan 7 Makara, City Phnom Penh
3[illegible]	SING LONG AGRICULTURE DEVELOPMENT IMPORT EXPORT CO LTD	Co 352[illegible] 97P	No 255E3Z, St Monivong, Sangkat Orussei 4, Khan 7 Makara, City Phnom Penh
3[illegible]	SINGLEAI CABLE TELEVISION CAMBODIA CO LTD	Co 1364 95P	No 132E2, St 128, Sangkat Monorom, Khan 7 Makara, City Phnom Penh
302	SINVIICO CAMBODIA LTD	Co 0242 97P	No 498, St 128, Sangkat Mittapheap, Khan 7 Makara, City Phnom Penh
303	SISOWATH LIE A GROUP - VAN DER MEER & ASSOCIATES LTD	Co 0085 93P	No 45, St 105, Sangkat Boeng Prolit, Khan 7 Makara, City Phnom Penh
304	SMILE CO LTD	Co 3688 98P	No 54EEo, St 109, Sangkat Orussei 3, Khan 7 Makara, City Phnom Penh
305	SOCIETE EUROPEENNE DE LIAISONS MARITIMES S E L M (S A	Co 0362 91	No 270, St 107, Sangkat Boeng Prolit, Khan 7 Makara, City Phnom Penh
306	SOK SAMY - VIKIMEX EXPORT EXPORT CO LTD	Co 04[illegible]8 93P	No 49, St 198, Sangkat Boeng Prolit, Khan 7 Makara, City Phnom Penh
307	SOKAH NAVY JEWELRY CO LTD	Co 1304 95P	No 126-128 Eo, St 128, Sangkat Monorom, Khan 7 Makara, City Phnom Penh
308	SOLARFA CAMBODIA DEVELOPMENT IN	[illegible] 04[illegible] 97P	No 15(IEo, St 215, Sangkat Veal Vong, Khan 7 Makara, City Phnom Penh
309	SOO HO INTERNATIONAL CORPORATION LTD	Co 3442 99P	No 101 CEoE1, St 2[illegible]4, Sangkat Boeng Prolit, Khan 7 Makara, City Phnom Penh
310	SOUNY CO LTD	Co 3282 97P	No 85, St 141, Sangkat Veal Vong, Khan 7 Makara, City Phnom Penh
311	SOUNEY IMPORT EXPORT CO LTD	Co 3[illegible]71 97P	No 19BEo, St 111, Sangkat Boeng Prolit, Khan 7 Makara, City Phnom Penh
312	SOUTH CHINA SEA GOLDEN DRAGON LTD	Co 15[illegible]2 95P	No 257Eo, St Sisowath, Sangkat Veal Vong, Khan 7 Makara, City Phnom Penh
313	SREANG SRENG (S S CO.,LTD)	Co 0446 93P	No 143, St 217, Sangkat Orussei 3, Khan 7 Makara, City Phnom Penh
314	SUM RONG WOOD PRODUCT CO LTD	Co 0059 93P	No 15-20Eo, St 164, Sangkat Orussei 3, Khan 7 Makara, City Phnom Penh
315	SUMATE - KAMPUCHEA NGOW HOCK CO LTD	Co 0240 93P	No 223Eo, St 93, Sangkat Orussei 4, Khan 7 Makara, City Phnom Penh
316	SUN FUA INTERNATIONAL TRADE CO.LTD	Co 0141 93	No 84 Eo, St 2[illegible]4, Sangkat Boeng Prolit, Khan 7 Makara, City Phnom Penh
317	SUPER WOOD I P E P LTD	Co 0838 94P	No 126BEo, St 156, Sangkat Veal Vong, Khan 7 Makara, City Phnom Penh
318	SURE SIDE CORPORATION INC	Co 1768 95P	No 19, St 205, Sangkat Teul Svay Prey 2, Khan Chamkarmorn, City Phnom Penh

319	SWISS GOLD CO.,LTD	Co [illegible]73/97P	No 85 Eo, St 214, Sangkat Boeng Prolit Khan 7 Makara City Phnom Penh
320	T.B.R ENTERPRISES CO.,LTD	Co [illegible]28/95P	No 37-38, St Monireth Sangkat Veal Vong Khan 7 Makara City Phnom Penh
321	T G N [illegible] G TRANSPORTATION & IMPORT EXPORT CO.,LTD	Co 0388/93P	No 3 Eo, St Sisowath 274, Sangkat Boeng Prolit Khan 7 Makara City Phnom Penh
322	TAI RICH DEVELOPMENT INVESTMENT UNITE CO.,LTD	Co [illegible]13/97P	No 268Eo, St 128 Sangkat Mittapheap Khan 7 Makara City Phnom Penh
323	TANG KHY HONG IMPORT EXPORT CO.,LTD	Co 1006/94P	No 371 Eo, St 93, Sangkat Orussei 4 Khan 7 Makara City Phnom Penh
324	TANG YU INVESTMENT & DEVELOPMENT CO.,LTD	Co 0223/97P	No 9 St 242, Sangkat Boeng Prolit Khan 7 Makara, City Phnom Penh
325	TAYOU INTERNATIONAL GROUP (CAMBODIA) DEVELPOMENT CO.,LTD	Co [illegible]095/96P	No 103, St [illegible]41, Sangkat Veal Vong Khan 7 Makara, City Phnom Penh
326	THAI JIE CAMBODIA CO.,LTD	Co [illegible]179/96P	No 212E2C, St [illegible], Sangkat Orussei 3 Khan 7 Makara, City Phnom Penh
327	THAI LONG DEVELOPMENT LTD	Co 1503/95P	No 61AE1, St 242, Sangkat Boeng Prolit, Khan 7 Makara City Phnom Penh
328	THAI PARQUET MARKETING CO.,LTD	Co 2211/96P	No 20, St 164 Sangkat Orussei 3 Khan 7 Makara City Phnom Penh
329	THONG NIM HENG IMPORT EXPORT CO.,LTD	Co 0763/94P	No 19, St 163 Sangkat Veal Vong Khan 7 Makara, City Phnom Penh
330	THY RITH TRADING CO.,LTD	Co 2429/96P	No 135 C St [illegible]8 Sangkat Monorom Khan 7 Makara City Phnom Penh
331	TIANLI INTERNATIONAL GROUP CO.,LTD	Co 1862/96P	No 10Eo St 111 Sangkat Boeng Prolit Khan 7 Makara City Phnom Penh
332	TIEN CHENG CO.,LTD	Co 1899/96P	No 114EEo, St 139 Sangkat Veal Vong, Khan 7 Makara City Phnom Penh
333	TONG LU TRADING IMPORT EXPORT CO.,LTD	Co 3352/97P	No 45, St 217 Sangkat Monorom, Khan 7 Makara, City Phnom Penh
334	TONG SING TOBACCO IMPORT EXPORT (CAMBODIA) CO.,LTD	Co 4040/98P	No 15-20 St 164, Sangkat Orussei 3 Khan 7 Makara City Phnom Penh
335	TOP GLORY (HOLDING) CO.,LTD	Co 1615/95P	No 13 14, St 164, Sangkat Orussei 3 Khan 7 Makara, City Phnom Penh
336	TOP ONE INVESTMENT LTD	Co 2101/96P	No 107 113 St Monivong, Sangkat Monorom, Khan 7 Makara City Phnom Penh
337	TOTRAMEX CO.,LTD	Co 1510/95P	No 50, St 111, Sangkat Boeng Prolit, Khan 7 Makara City Phnom Penh
338	ULTRA RASMY CO.,LTD	Co 1706/95P	No 32E2, St 168, Sangkat Orussei 1, Khan 7 Makara, City Phnom Penh

339	UNION CONTRUCTION CO.,LTD	Co 2155 96P	No 202E1, St Kampuchea Krom, Sangkat Mittapheap, Khan 7 Makara City Phnom Penh
340	UNION LINK PAGING COMPANY LTD	INV 01 9 96E	No 251, St 128 Sangkat Mittapheap Khan 7 Makara City Phnom Penh
341	UNIPROD ENTERPRISES CO. LTD	Inv 0299 97P	No 25, St 211, Sangkat Veal Vong, Khan 7 Makara City Phnom Penh
342	UNITED COMMUNICATION INTERNATIONAL CO LTD	Co 1[illegible] 94P	No 336Eo St 128 Sangkat Mittapheap, Khan 7 Makara City Phnom Penh
343	UNITED NEW ASIA GROUP COMPANY, LTD	C[illegible]07[illegible] 94P	No 33, St 122 Sangkat Mittapheap Khan 7 Makara, City Phnom Penh
344	UNITED TRADIANG IMPORT EXPORT CO.,LTD	Co 3719 95P	No 382 St Kampuchea Krom, Sangkat Mittapheap, Khan 7 Makara City Phnom Penh
345	VENG HUA HONG IMPORT EXPORT CO.,LTD	Co 0705 94P	No 107Eo, St 107, Sangkat Orussei 4, Khan 7 Makara, City Phnom Penh
346	VISA SERVICE INTERNATIONAL INC LTD	Co 2450 96P	No 429E1, St Monivong, Sangkat Boeng Prolit Khan 7 Makara, City Phnom Penh
347	WAN THAI INTERNATIONAL INVESTMENT AND DEVELOPMENT CO.,LTD	Co 2315 96P	No Theang Lon, St 232, Sangkat Boeng Prolit, Khan 7 Makara City Phnom Penh
348	WINCO POWER SYSTEM LIMITED	Co 0[illegible]0 97E	No 155Eo, St Kampuchea Krom Sangkat Mittapheap Khan 7 Makara, City Phnom Penh
349	WINICAN HOLDING LTD	Co 1731 95P	No 165-167 E1, St 93, Sangkat Monorom Khan 7 Makara, City Phnom Penh
350	XIE YI (CAMBODIA) PTE.LTD	[illegible] 1[illegible] 96P	No 174EIZ St 217, Sangkat Orussei 3 Khan Makara City Phnom Penh
351	XINLONG INDUSTRAL CO.,LTD	[illegible]53 99E	No 363EoZ, St 93 Sangkat Orussei 4 Khan 7 Makara City Phnom Penh
352	XU HUA CAMBODIA CO. LTD	Co 2[illegible]3 96P	No 123Eo, St Sihanouk, Sangkat Boeng Prolit Khan 7 Makara City Phnom Penh
353	Y & D HEIWA TRADING TRANSPORTATION AND CONSTUCTION CO LTD	Co 0883 94P	No 278Eo St 128, Sangkat Mittapheap, Khan 7 Makara, City Phnom Penh
354	Y AN IMPORT EXPORT CO LTD	Co 1689 95P	No 419B bis E, St 93 Sangkat Boeng Prolit, Khan 7 Makara City Phnom Penh
355	YA THAI INTERNATIONAL Import Export Co.,Ltd	Co 4540 99P	No 275 E1, St 128, Sangkat Mittapheap, Khan 7 Makara, City Phnom Penh
356	YOUNG CORP LTD	Co 000[illegible] 02P	No 17 Eo, St 170, Sangkat Orussei 1 Khan 7 Makara, City Phnom Penh
357	YU SHAN CONSTRUCTION CAMBODIA COMPANY,LTD	Co 1415 95P	No 2, St 211&146, Sangkat Veal Vong, Khan 7 Makara, City Phnom Penh
358	ZHEA HER AGRICULTURE CO.,LTD	Co 1801 95P	No 11E2, St 170, Sangkat Orussei 3, Khan 7 Makara, City Phnom Penh

359	ZHI YAN IMPORT EXPORT CO.,LTD	Co 1996/96P	No Room 107, St 63, Sangkat Veal Vong Khan 7 Makara, City Phnom Penh
360	ZHIYOU INTERNATIONAL CO.,LTD	Co 17.0 95P	No , St 217, Sangkat Orusse. 2, Khan 7 Makara, City Phnom Penh
361	ZHIJIAN MARKETING (CAMBODIA) CO.,LTD	Co 2332/96P	No 430Eo, St 128, Sangkat Mittapheap, Khan 7 Makara, City Phnom Penh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

****

ក្រសួងផែនការ និង ក្រសួងពាណិជ្ជកម្ម

លេខៈ ១៧៩ ប្រក.ផក.ពណ

ភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤

ប្រកាសរួម

ស្តីពី

វិធានការគ្រប់គ្រងភាពសមស្របតាមបណ្តាលក្ខខណ្ឌតម្រូវនៃការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ

****

រដ្ឋមន្ត្រីក្រសួងផែនការ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផល ទំនិញ និងសេវា
- បានឃើញ អនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ

បានឃើញ អនុក្រឹត្យលេខ ៥៤អនក្រ បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

បានឃើញ អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ស្តីពី ការបង្កើតក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ

- បានឃើញ អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យនៃម្ហូបអាហារសំរាប់មនុស្ស

- បានឃើញ អនុក្រឹត្យលេខ ៦៩អនក្រ បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ

បានឃើញ ប្រកាសលេខ ៣០ ក.ជ.អ.ជ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពីនីតិវិធីគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ

បានឃើញ ប្រកាសលេខ ០១២ ពណ.បល.ប្រក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ដើម្បីប្រសិទ្ធភាពនៃការត្រួតពិនិត្យលក្ខខ័ណ្ឌតម្រូវនៃអំបិលអ៊ីយ៉ូដដែលធ្វើអាជីវកម្ម ។

សំរេច

ប្រការ១.

គ្រប់ប្រភេទអំបិលផលិតក្នុងប្រទេស និងនាំចូលពីបរទេស ចាំបាច់ត្រូវតែបញ្ចូលជាតិអ៊ីយ៉ូដ មុននឹងធ្វើការលក់ចែកចាយដុំនិងរាយនៅតាមទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា តាមស្តង់ដារកំណត់ ដូចខាងក្រោមនេះ :

សំណើមក្នុងអំបិលមិនត្រូវលើសពី ៥%

ត្រូវមានសូដ្យូមក្លរ NaCl យ៉ាងតិច ៩៧% គិតតាមទម្ងន់អំបិលស្ងួត

មិនត្រូវមានម៉ាញ៉េស្យូមក្លរ $MgCl_2$ លើសពី ០.៥%

មិនត្រូវមានសារធាតុមិនរលាយក្នុងទឹកលើសពី ០.២%

មិនត្រូវមានសារធាតុពុលផ្សេងៗលើសពីស្តង់ដាររបស់ជាតិឡើយ

ត្រូវមានសារធាតុអ៊ីយ៉ូដចំនួន :

៥០ ៦០ មីលីក្រាម ក្នុង១គីឡូក្រាមអំបិល ពិនិត្យឃើញនៅកន្លែងផលិត

- ៣០ ៦០ មីលីក្រាម ក្នុង១គីឡូក្រាមអំបិល ពិនិត្យឃើញនៅតាមកន្លែងលក់ដុំ និងលក់រាយ ។

ប្រការ២.

មុននឹងចេញលក់នៅលើទីផ្សារ ផលិតករ អាជីវករទាំងអស់ ត្រូវវេចខ្ចប់អំបិលអ៊ីយ៉ូដ និងផ្សារភ្ជិតយ៉ាងត្រឹមត្រូវក្នុងថង់ផ្លាស្ទិកប៉ូលីអេទីឡែន សំរាប់ប្រភេទទំងន់ ០.៥គក្រ និង ១គក្រ និងបាវផ្លាស្ទិកប៉ូលិប្រូពីឡែន ដែលមាន ស្រទាប់ផ្លាស្ទិកប៉ូលីអេទីឡែននៅខាងក្នុង សំរាប់ប្រភេទទំងន់ ២៥គក្រ និង ៥០គក្រ និងត្រូវប្រតិបត្តិតាមល័ក្ខខ័ណ្ឌកំណត់ ដូចមានចែងក្នុងមាត្រាទី៩ និងទី១០ នៃអនុក្រឹត្យ ៦៩ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រង ការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ ។

ប្រការ៣.

ផលិតករអំបិល ត្រូវធានាបង្កើនគុណភាព និងផលិតភាពអំបិល ព្រមទាំងអនុវត្តការបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិលដើម្បីបំពេញនូវតំរូវការប្រើប្រាស់ទូទាំងប្រទេស ។

ប្រការ៤.

អាជីវករអំបិលត្រូវទិញនិងលក់តែអំបិលដែលមានជាតិអ៊ីយ៉ូដ ព្រមទាំងធានានូវគុណភាព និងសុវត្ថិភាព សមស្របតាមស្តង់ដារ និងល័ក្ខខ័ណ្ឌកំណត់ដូចមានចែងក្នុងប្រការ ១ និងប្រការ២ ។

ប្រការ៥.

ក្នុងក្របខ័ណ្ឌនៃការទទួលខុសត្រូវរបស់ខ្លួន ផលិតករត្រូវអនុវត្តន៍ឱ្យបានត្រឹមត្រូវនូវបញ្ញត្តិអំពី ស្តង់ដារអំបិលកូណៈ និងភាពស្អាតនៃសំបកវេចខ្ចប់ អំពីស្លាកសញ្ញាលើសំបកវេចខ្ចប ដែលមានចែងក្នុងប្រការ ១ និងប្រការ២ និងខ្លឹមសារលំអិតមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទិ ២០ ខែតុលា ឆ្នាំ២០០៣ ស្តីពី ការគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ និងដើម្បីជាមូលដ្ឋានសំរាប់ការត្រួតពិនិត្យ ដោយមន្ត្រីនាយកដ្ឋានកាំកុងត្រូល សហការជាមួយក្រសួងពាក់ព័ន្ធ ។ ស្របតាមល័ក្ខខ័ណ្ឌកំណត់ដូចខាងលើ សហគ្រាសផលិតទាំងឡាយ ដែលបានទទួលការអនុញ្ញាតផលិតអំបិលអ៊ីយ៉ូដ (IODINE) ត្រូវ :

១ កត់ត្រាក្នុងសៀវភៅបញ្ជីមួយនូវ :

បរិមាណអំបិលជាវត្ថុធាតុដើមសំរាប់សង្វាកផលិតកម្មក្នុងឡូត៍និមួយៗ ។

-បរិមាណសារធាតុសូដ្យូមអ៊ីយ៉ូដូរ ឬប៉ូតាស្យូមអ៊ីយ៉ូដូរ ឬសូដ្យូមអ៊ីយ៉ូដាត ឬប៉ូតាស្យូមអ៊ីយ៉ូដាត ដែលបានទទួលដោយមានរបាយការណ៍ពាក់ព័ន្ធជាមួយ ។

បរិមាណសារធាតុសូដ្យូមអ៊ីយ៉ូដូរ ឬប៉ូតាស្យូមអ៊ីយ៉ូដូរ ឬសូដ្យូមអ៊ីយ៉ូដាត ឬប៉ូតាស្យូមអ៊ីយ៉ូដាត ប្រើប្រាស់ប្រចាំថ្ងៃ និងតាមឡូត៍និមួយៗ ។

បរិមាណអំបិលមានបញ្ចូល IODINE ផលិតបានប្រចាំថ្ងៃ និងតាមមន្ត្រីនិមួយៗ ។

ខ -ធ្វើការត្រួតពិនិត្យភាពត្រឹមត្រូវតាមស្តង់ដារនៃផលិតផលសំរេចជាអាទិ៍ សំណើមនិងកំរិតជាតិអ៊ីយ៉ូដក្នុងអំបិលទម្ងន់ក្នុងបាវតាមចំនួនគំរូតាមសង្កាក់ដែលយល់ថាសមរម្យដោយកត់ត្រានិងរក្សាឯកសារបញ្ជាក់ លទ្ធផលនៃការត្រួតពិនិត្យនិមួយៗនោះ ។

ប្រការ៦.

នៅកន្លែងស្តុកទុក នៅកន្លែងលក់ដុំ អាជីវករជាម្ចាស់អំបិលត្រូវមានវិក្កយប័ត្របញ្ជាក់ ប្រភពដើមកន្លែងផលិតអំបិលអ៊ីយ៉ូដ ដែលចេញដោយអាជីវករ រោងចក្រ សហគ្រាស សិប្បកម្ម ដែលបានទទួលការអនុញ្ញាតផលិតអំបិលអ៊ីយ៉ូដ និងលិខិតអះអាង អំពីភាពសមស្របរបស់អំបិល ពីរោងចក្រ សហគ្រាសសិប្បកម្មបញ្ចូលសារធាតុអ៊ីយ៉ូដ ។

ប្រការ៧.

ការដឹកជញ្ជូនអំបិលធម្មតាដើម្បីយកមកបញ្ចូលសារធាតុអ៊ីយ៉ូដ នៅរោងចក្រ សហគ្រាស សិប្បកម្មផ្សេងៗ ដែលមានទីតាំងស្ថិតនៅក្នុងទីរួមខេត្តកំពត និងក្រុងកែប ត្រូវមានវិក័យបត្រ និងលិខិតដឹកជញ្ជូនត្រឹមត្រូវចេញដោយម្ចាស់សហគ្រាសហើយមានបញ្ជាក់ ជាអាទិ៍នូវទិសដៅដឹកជញ្ជូនគឺ ទីតាំងរបស់រោងចក្រ សហគ្រាស សិប្បកម្ម ដែលទទួលបញ្ចូលសារធាតុអ៊ីយ៉ូដ និងត្រូវសរសេរ ឬ បោះពុម្ពពាក្យថា អំបិលនេះពុំទាន់មានគុណភាពគ្រប់គ្រាន់សំរាប់បរិភោគរបស់មនុស្ស និងសត្វទេ ។

ប្រការ៨.

រាល់ការដឹកជញ្ជូនអំបិលធម្មតាយកទៅស្តុកទុក សំរាប់បញ្ចូលសារធាតុអ៊ីយ៉ូដ នៅរោងចក្រ សហគ្រាស សិប្បកម្ម ដែលបានទទួលការអនុញ្ញាត ហើយមានទីតាំងនៅក្នុងទីរួមខេត្តកំពត និងក្រុងកែប ត្រូវមានការអនុញ្ញាតជាមុន ពីនាយកដ្ឋានកាំកុងត្រូល លើមូលដ្ឋាននៃការចុះសិក្សាទិន្នន័យបច្ចេកទេសនិងអាជីវកម្មរបស់សហគ្រាសផលិតនោះ ។

សាខាកាំកុងត្រូលខេត្តកំពត ដែលត្រូវចុះទិដ្ឋាការគ្រប់គ្រងសកម្មភាពដឹកជញ្ជូននេះ ត្រូវកត់ត្រាលើបរិមាណស្តុកឱ្យបានទៀងទាត់តាមបរិមាណដឹកចេញពីចំនួនដែលត្រូវបានអនុញ្ញាតជាគោលការណ៍ ។

ប្រការ៩.

រាល់អាជីវកម្មលក់ដុំអំបិលអ៊ីយ៉ូដ ក្រៅពីត្រូវមានការចុះបញ្ជីពាណិជ្ជកម្មតាមបញ្ញត្តិ ច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្មត្រូវមានការប្រកាសសុំធ្វើអាជីវកម្មលក់ដុំអំបិលអ៊ីយ៉ូដនៅសាខាកាំកុងត្រូល នៃកន្លែងធ្វើអាជីវកម្ម ដោយផ្ដល់នូវគ្រប់ព័ត៌មានមានប្រយោជន៍សំរាប់ការត្រួតពិនិត្យជាអាទិ៍ :

- អត្តសញ្ញាណប័ណ្ណ អាស័យដ្ឋានរបស់អាជីវករ
- ទីតាំងសំរាប់អាជីវកម្មលក់ដុំ ឬស្តុក

ការអះអាងលើវចនាបថរបស់ទីតាំងដែលអាចធានាការទុកដាក់អំបិលអ៊ីយ៉ូដ ក្នុងលក្ខណៈមិនបាត់បង់នូវសារធាតុអ៊ីយ៉ូដពីអំបិល ។

អាជីវករលក់ដុំអំបិលអ៊ីយ៉ូដ ត្រូវរក្សាវិក័យប័ត្របញ្ជាក់ប្រភពរបស់អំបិល ឯកសារដឹកជញ្ជូនប្រគល់-ទទួលអំបិល ឯកសារត្រួតពិនិត្យបញ្ជាក់គុណភាពអំបិលឱ្យបានត្រឹមត្រូវ សំរាប់តំរូវការរបស់មន្ត្រីកាំកុងត្រូលពេលត្រួតពិនិត្យ ។

ប្រការ១០.

ការនាំចូលអំបិលធ្វើបានតាមប្រក្រតីតែចំពោះអំបិលមានបញ្ចូលសារធាតុអ៊ីយ៉ូដ (IODINE) ហើយអាជីវករនាំចូលត្រូវធ្វើការប្រកាសបំពេញបែបបទត្រួតពិនិត្យ នៅនាយកដ្ឋានកាំកុងត្រូលពេលទំនិញមកដល់ ។

រាល់ការបញ្ជូនអំបិលតាមមធ្យោបាយនិមួយៗ ត្រូវមានភ្ជាប់បន្ថែមលើឯកសារពាណិជ្ជកម្មពាក់ព័ន្ធនូវវិញ្ញាបនប័ត្របញ្ជាក់ភាពសមស្របតាមស្តង់ដារកំណត់ក្នុងប្រការ១ ។

អត្រាសារធាតុអ៊ីយ៉ូដនៅលើមធ្យោបាយដឹកជញ្ជូន នៅកន្លែងប្រគល់-ទទួល ត្រូវស្មើនឹងកំរិតសារធាតុអ៊ីយ៉ូដ ដែលពិនិត្យឃើញនៅកន្លែងផលិត គឺ៥០ ៦០ មីលីក្រាម ក្នុងមួយគីឡូក្រាមអំបិល ។

រាល់ការអនុញ្ញាតឱ្យទទួលចូលឃ្លាំងត្រូវធ្វើក្នុងលក្ខណៈជាប់ល័ក្ខខ័ណ្ឌ នៃការមានភាពសមស្របត្រួតពិនិត្យឃើញបន្ថែមទៀតនៅឃ្លាំងស្តុក ។

ប្រការ១១.

ក្រសួងផែនការ ត្រូវសហការជាមួយក្រសួងព័ត៌មាន ដើម្បីជំរុញផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីឥទ្ធិពលនៃបញ្ហាកង្វះជាតិអ៊ីយ៉ូដ និងសារៈសំខាន់នៃការប្រើប្រាស់អំបិលអ៊ីយ៉ូដ តាមគ្រប់វិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី ព្រឹត្តិប័ត្រ សារព័ត៌មាន និងប្រព័ន្ធព័ត៌មាននានា ។

មន្ត្រីត្រួតពិនិត្យនៃនាយកដ្ឋានកាំកុងត្រូល ត្រូវកសាងកម្មវិធីត្រួតពិនិត្យជាក់លាក់នៅគ្រប់រោងចក្រ សហគ្រាស សិប្បកម្ម ផលិតអំបិលអ៊ីយ៉ូដ នៅកន្លែងស្តុក កន្លែងលក់ដុំ តាមទីផ្សារ សំដៅធានាអោយការអនុវត្តនីនូវបទបញ្ញត្តិសំរាប់អាជីវកម្មអំបិលអ៊ីយ៉ូដ បានត្រឹមត្រូវ ។

មន្ត្រីនាយកដ្ឋានកាំកុងត្រូល ត្រូវមានកម្មវិធីធ្វើការផ្សព្វផ្សាយអំពី ឥទ្ធិពលនៃបញ្ហាកង្វះជាតិអ៊ីយ៉ូដ និងសារៈសំខាន់នៃការប្រើប្រាស់អំបិលអ៊ីយ៉ូដ អោយបានសកម្ម ពិសេសសំរាប់ប្រជាពលរដ្ឋនៅជនបទ ។

នាយកដ្ឋានកាំកុងត្រូល ត្រូវខិតខំប្រមូលពត៌មាននានា ធ្វើការវិភាគផ្តល់យោបល់សមហេតុផល មានប្រយោជន៍សំរាប់ពង្រឹងគំរោងអំបិលអ៊ីយ៉ូដជូនក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ និងគណៈកម្មាធិការសំរបសំរួលការងារអាហារូបត្ថម្ភខេត្ត ក្រុង ។

ប្រការ១២.

ប្រធានគណៈកម្មការបច្ចេកទេសអន្តរក្រសួង គណៈកម្មាធិការសំរបសំរួលការងារអាហារូបត្ថម្ភខេត្ត ក្រុង អគ្គនាយកបច្ចេកទេសនៃក្រសួងពាណិជ្ជកម្ម ប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ ប្រធាននាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញទីហរ័ណ-អាហរ័ណ និង បង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រីក្រសួងផែនការ

ឆាយ ថន

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

វង្ស ម៉ុន្ធារា

កន្លែងទទួល:

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់ខេត្ត ក្រុង
- "ដូចប្រការ១២" ដើម្បីអនុវត្ត
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣ ❀ ៣៣៣

ក្រសួងអប់រំ យុវជន និង កីឡា
លេខ: ៦៩៥ អយក.ប្រក.

ប្រកាស
ស្តីពីការកំណត់មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញព្រះរាជក្រមលេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រមលេខ នស/_កម ០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា ។

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និងកីឡា ។

-បានឃើញព្រះរាជក្រឹត្យលេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។

-បានឃើញលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១៨៥២ សជណ.អវ ចុះថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការលុបការប្រលងសញ្ញាប័ត្រមធ្យមសិក្សាលើកទី២ ។

-បានឃើញប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាលេខ ៦៨៩ អយក.ប្រក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។

-យោងសំណើរបស់មន្ទីរអប់រំយុវជន និង កីឡាខេត្ត_ក្រុង ស្តីពីការសុំបើកមណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ តាមខេត្ត_ក្រុង ។

សំរេច

ប្រការ ១ :មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិចំនេះទូទៅ និងបំពេញវិជ្ជា សម័យប្រលង : ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៤ ត្រូវកំនត់ដូចតទៅ ÷

I. រាជធានីភ្នំពេញ មាន១០មណ្ឌល :

១ - មណ្ឌល វិ. បឹងត្របែក	៤២បន្ទប់	ខ័ណ្ឌចំការមន

៥

២ -	មណ្ឌល វិ.ទួលទំពូង	៤២បន្ទប់		ខណ្ឌចំការមន
៣	មណ្ឌល វិ.ហ៊ុនសែន-ប៊ុនរ៉ានី វត្តភ្នំ	៤២បន្ទប់		ខណ្ឌដូនពេញ
៤ -	មណ្ឌល វិ.វត្តកោះ	៤០បន្ទប់		ខណ្ឌដូនពេញ
៥ -	មណ្ឌល អនុវិ.ចតុមុខ	៤០បន្ទប់		ខណ្ឌដូនពេញ
៦ -	មណ្ឌល វិ.ព្រះស៊ីសុវត្ថិ	៤១បន្ទប់	ក្នុងនោះមានស្ម័យរិន និងបំ.វិ.	ខណ្ឌដូនពេញ
៧ -	មណ្ឌល វិ.សន្ធរម៉ុក	៤០បន្ទប់		ខណ្ឌទួលគោក
៨ -	មណ្ឌល វិ.ឥន្ទ្រទេវី	៤០បន្ទប់		ខណ្ឌទួលគោក
៩ -	មណ្ឌល វិ.បាក់ទូក	៤០បន្ទប់		ខណ្ឌ ៧មករា
១០ -	មណ្ឌល បឋម.បាក់ទូក	៣៨បន្ទប់		ខណ្ឌ ៧មករា

II. ខេត្តកណ្ដាល មាន០៦មណ្ឌល :

១ -	មណ្ឌល វិ.កំពង់កន្ទួត	២០បន្ទប់		ស្រុកកណ្ដាលស្ទឹង
២ -	មណ្ឌល អនុវិ.សេរីភាព	២៤បន្ទប់		ស្រុកតាខ្មៅ
៣ -	មណ្ឌល វិ.ហ៊ុន សែន តាខ្មៅ	២៥បន្ទប់	ក្នុងនោះមានស្ម័យរិន និងបំ.វិ.	ស្រុកតាខ្មៅ
៤ -	មណ្ឌល វិ.ជ័យវរ្ម័នទី៧	២៨បន្ទប់		ស្រុកកៀនស្វាយ
៥	មណ្ឌល វិ.ហ៊ុន សែន ខ្សាច់កណ្ដាល	២២បន្ទប់		ស្រុកខ្សាច់កណ្ដាល
៦	មណ្ឌល វិ.ហ៊ុន សែន អង្គស្នួល	១៥បន្ទប់		ស្រុកអង្គស្នួល

III. ខេត្តកំពង់ចាម មាន០៧មណ្ឌល :

១ -	មណ្ឌល វិ.ព្រះសីហនុ	៤២បន្ទប់	ក្នុងនោះមានស្ម័យរិន និងបំ.វិ.	ស្រុកកំពង់ចាម
២ -	មណ្ឌល បឋម.ទក្សិណ	១២បន្ទប់		ស្រុកកំពង់ចាម
៣ -	មណ្ឌល វិ.នរោត្តមរណប្ញទ្ធិ-គន្ធបុប្ផា	២១បន្ទប់		ស្រុកព្រៃឈរ
៤ -	មណ្ឌល វិ.ហ៊ុន សែន ស្គន់	១០បន្ទប់		ស្រុកជើងព្រៃ
៥ -	មណ្ឌល វិ.ហ៊ុន សែន ពាមជីកង	១៦បន្ទប់		ស្រុកកងមាស
៦	មណ្ឌល វិ.ជីហែ	១៥បន្ទប់		ស្រុកកោះសូទិន
៧ -	មណ្ឌល វិ.ត្បូងឃ្មុំ	៣១បន្ទប់		ស្រុកត្បូងឃ្មុំ

IV. ខេត្តតាកែវ មាន០៧មណ្ឌល :

១ -	មណ្ឌល វិ.ជា ស៊ីម តាកែវ	២៧បន្ទប់	ក្នុងនោះមាន ស្ម័យរិន	ស្រុកដូនកែវ
២ -	មណ្ឌល វិ.១ឧសភា	២៥បន្ទប់		ស្រុកត្រាំកក់
៣ -	មណ្ឌល វិ.សម្ដេចនី	២២បន្ទប់		ស្រុកសំរោង
៤ -	មណ្ឌល វិ.ប៊ុនរ៉ានី-ហ៊ុនសែន បាទី	១៥បន្ទប់		ស្រុកបាទី
៥ -	មណ្ឌល វិ.ព្រៃសណ្ដែក	១៧បន្ទប់		ស្រុកទ្រាំង
៦ -	មណ្ឌល បឋម.សុខអាន ទន្លាប់	១៥បន្ទប់		ស្រុកគិរីវង់

៧ -	មណ្ឌល វិ.ហេង សំរិន ព្រៃល្វា	១៧បន្ទប់		ស្រុកព្រៃកប្បាស

V. ខេត្តបាត់ដំបង មាន០៥មណ្ឌល :

១ -	មណ្ឌល វិ.ព្រះមុនីវង្ស	២៥បន្ទប		ស្រុកបាត់ដំបង
២ -	មណ្ឌល វិ.នេតយ៉ង់	៣០បន្ទប		ស្រុកបាត់ដំបង
៣ -	មណ្ឌល អនុវិ.សោហ៊ី	១៨បន្ទប់	ក្នុងនោះមាន ស៊ូយិន	ស្រុកបាត់ដំបង
៤ -	មណ្ឌល វិ.សម្តេចឪ	១៨បន្ទប	ក្នុងនោះមាន បំពេញវិជ្ជា	ស្រុកបាត់ដំបង
៥ -	មណ្ឌល មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ	២៥បន្ទប់		ស្រុកបាត់ដំបង

VI. ខេត្តព្រៃវែង មាន០៤មណ្ឌល :

១ -	មណ្ឌល វិ.ព្រះអង្គឌួង	៣០បន្ទប់		ស្រុកកំពង់លាវ
២ -	មណ្ឌល វិ.ហ៊ុន សែន កំពង់លាវ	២១បន្ទប	ក្នុងនោះមានស៊ូយិន និងបំ.វិ.	ស្រុកកំពង់លាវ
៣ -	មណ្ឌល វិ.បាភ្នំ	១៩បន្ទប		ស្រុក បាភ្នំ
៤ -	មណ្ឌល វិ.ហ៊ុន សែន ពាមរក	២៥បន្ទប		ស្រុក ព្រះស្ដេច

VII. ខេត្តបន្ទាយមានជ័យ មាន០៤មណ្ឌល :

១ -	មណ្ឌល វិ.ហ៊ុន សែន មង្គលបុរី	១៩បន្ទប់		ស្រុកមង្គលបុរី
២ -	មណ្ឌល អនុវិ.ទឹកថ្លា	១០បន្ទប		ស្រុកសិរីសោភ័ណ
៣ -	មណ្ឌល វិ.សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ អូរអំបិល	១០បន្ទប		ស្រុកសិរីសោភ័ណ
៤ -	មណ្ឌល វិ.សម្តេចឪ	១៧បន្ទប	ក្នុងនោះមាន ស៊ូយិន	ស្រុកសិរីសោភ័ណ

VIII. ខេត្តកំពត មាន០៥មណ្ឌល :

១ -	មណ្ឌល បឋម.កំពតក្រុង	១៩បន្ទប់		ស្រុកកំពង់បាយ
២ -	មណ្ឌល បឋម.ជុំគ្រៀល	១៧បន្ទប	ក្នុងនោះមាន ស៊ូយិន	ស្រុក កំពត
៣ -	មណ្ឌល វិ.ហ៊ុន សែន ឈូក	១៩បន្ទប		ស្រុក ឈូក
៤	មណ្ឌល វិ.ជា ស៊ីម អង្គរជ័យ	២១បន្ទប់		ស្រុក អង្គរជ័យ
៥ -	មណ្ឌល វិ.ទូកមាស	១៤បន្ទប់		ស្រុក ទូកមាស

IX. ខេត្តកំពង់ស្ពឺ មាន០៣មណ្ឌល :

១ -	មណ្ឌល វិ.កំពង់ស្ពឺ	១១បន្ទប់		ស្រុកច្បារមន
២ -	មណ្ឌល បឋម.សន្តិភាព	២០បន្ទប		ស្រុកច្បារមន
៣ -	មណ្ឌល អនុវិ.ទីរួមខេត្ត	២៣បន្ទប់	ក្នុងនោះមាន ស៊ូយិន	ស្រុកច្បារមន

X. ខេត្តកំពង់ធំ មាន០៤មណ្ឌល :

១ -	មណ្ឌល បឋម.កំពង់ធំក្រុង	២០បន្ទប		ស្រុកស្ទឹងសែន
២ -	មណ្ឌល វិ.ហ៊ុន សែន បល្ល័ង្ក	១៧បន្ទប់	ក្នុងនោះមាន ស៊ូយិន	ស្រុកស្ទឹងសែន
៣ -	មណ្ឌល បឋម.អនុវិ.ហ៊ុន សែន អាចារ្យលាក់	១៤បន្ទប់		ស្រុកស្ទឹងសែន

៤ - មណ្ឌល វិ. កំពង់ធំ	២៦បន្ទប់		ស្រុកស្ទឹងសែន

XI. ខេត្តសៀមរាប មាន០២មណ្ឌល :

១ - មណ្ឌល បឋម. វត្តបូព៌	៣៣បន្ទប់		ស្រុកសៀមរាប
២ - មណ្ឌល អនុវិ. អង្គរ	៣៦បន្ទប់	ក្នុងនោះមាន ស៊ីយ៉ាន	ស្រុកសៀមរាប

XII. ខេត្តស្វាយរៀង មាន០៤មណ្ឌល :

១ - មណ្ឌល បឋម. ២ធ្នូ	២០បន្ទប់		ស្រុកស្វាយរៀង
២ - មណ្ឌល បឋម. កន្ទុយរៃ	១៣បន្ទប់		ស្រុកស្វាយជ្រំ
៣ - មណ្ឌល អនុវិ. ចេក	០៧បន្ទប់		ស្រុកស្វាយរៀង
៤ - មណ្ឌល បឋម. ព្រះសីហនុ	២៥បន្ទប់	ក្នុងនោះមានស៊ីយ៉ាន និងបំ.វិ.	ស្រុកស្វាយរៀង

XIII. ខេត្តពោធិ៍សាត់ មាន០២មណ្ឌល :

១ - មណ្ឌល អនុវិ. ពោធិ៍សាត់	២៨បន្ទប់		ស្រុកសំពៅមាស
២ - មណ្ឌល បឋម. ពោធិ៍សាត់	១៣បន្ទប់	ក្នុងនោះមានស៊ីយ៉ាន និងបំ.វិ.	ស្រុកសំពៅមាស

XIV. ខេត្តកំពង់ឆ្នាំង មាន០២មណ្ឌល :

១ - មណ្ឌល វិ. ព្រះបាទសុរាម្រឹត	២២បន្ទប់		ស្រុកកំពង់ឆ្នាំង
២ - មណ្ឌល វិ. ប៊ុនរ៉ានី-ហ៊ុនសែន រលាប្អៀរ	២០បន្ទប់	ក្នុងនោះមាន ស៊ីយ៉ាន	ស្រុករលាប្អៀរ

XV. ក្រុងព្រះសីហនុ មាន០១មណ្ឌល :

១ - មណ្ឌល បឋម. កម្មករ	២២បន្ទប់	ក្នុងនោះមាន ស៊ីយ៉ាន	ខណ្ឌមិត្តភាព

XVI. ខេត្តក្រចេះ មាន០២មណ្ឌល :

១ - មណ្ឌល វិ. ព្រះមហាក្សត្រិយានីកុសុមៈ	២២បន្ទប់	ក្នុងនោះមាន ស៊ីយ៉ាន	ស្រុកទីរួមខេត្ត
២ - មណ្ឌល អនុវិ. ក្រចេះក្រុង	១៤បន្ទប់		ស្រុកទីរួមខេត្ត

XVII. ខេត្តស្ទឹងត្រែង មាន០១មណ្ឌល :

១ - មណ្ឌល បឋម. អនុវត្ត	០៨បន្ទប់	ក្នុងនោះមាន ស៊ីយ៉ាន	ស្រុកស្ទឹងត្រែង

XVIII. ខេត្តកោះកុង មាន០២មណ្ឌល :

១ - មណ្ឌល វិ. កោះកុង	០៤បន្ទប់	ក្នុងនោះមាន ស៊ីយ៉ាន	ស្រុកស្មាច់មានជ័យ
២ - មណ្ឌល វិ. ស្រែអំបិល	០១បន្ទប់		ស្រុកស្រែអំបិល

XIX. ព្រះវិហារ មាន០១មណ្ឌល :

១ - មណ្ឌល វិ. ជា ស៊ីម ត្បែងមានជ័យ	១០បន្ទប់	ក្នុងនោះមាន បំពេញវិជ្ជា	ស្រុកត្បែងមានជ័យ

XX. ខេត្តរតនគិរី មាន០១មណ្ឌល :

១ - មណ្ឌល វិ. សម្ដេចឪ សម្ដេចម៉ែ	០៣បន្ទប់		ស្រុកបានលុង

XXI. ក្រុងកែប មាន០១មណ្ឌល :

១ - មណ្ឌល អនុវិ. សង្គមរាស្ត្រនិយម	០៤បន្ទប់	ក្នុងនោះមាន ស៊ីយ៉ាន	ខណ្ឌ កែប

XXII. ខេត្តមណ្ឌលគិរី មាន ០១ មណ្ឌល :

១ - មណ្ឌល វិ.ហ៊ុន សែន មណ្ឌលគិរី ០១បន្ទប់ ស្រុកសែនមនោរម្យ

XXIII. ក្រុងប៉ៃលិន មាន ០១ មណ្ឌល :

១ - មណ្ឌល វិ.ក្រុងទេពនិម្មិត ហ៊ុន សែន ០២បន្ទប់ ស្រុកប៉ៃលិន

XXIV. ខេត្តឧត្តរមានជ័យ មាន ០១ មណ្ឌល :

១ - មណ្ឌល វិ.ឧត្តរមានជ័យ ០៤បន្ទប់ ស្រុកសំរោង

ប្រការ ២ : មន្ទីរអប់រំយុវជន និង កីឡាខេត្ត-ក្រុង និងគ្រឹះស្ថានសិក្សារបស់ខ្លួន ដែលត្រូវយកធ្វើជាមណ្ឌលប្រលងមានភារកិច្ចរៀបចំមណ្ឌលប្រលង និងសំភារៈចាំបាច់សំរាប់ការប្រព្រឹត្តទៅនៃការប្រលង អោយហើយស្រេចស្រេច មុនបើកសម័យប្រលង ។

ប្រការ ៣ : មន្ទីរអប់រំយុវជន និង កីឡាខេត្ត-ក្រុង ត្រូវទាក់ទងជាមួយអាជ្ញាធរដែនដី ដើម្បីរៀបចំកំលាំងថែរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាពតាមមណ្ឌលប្រលង អោយហើយស្រេច មុនបើកសម័យប្រលង ។

ប្រការ ៤ : អគ្គនាយកអប់រំ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអប់រំយុវជន និង កីឡា ត្រូវអនុវត្តតាមភារកិច្ចរៀងៗខ្លួន ដើម្បីអោយបានសំរេចតាមប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៤

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

ចំលងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីសូមជ្រាបជាពត៌មាន"
- សាលាខេត្ត-ក្រុង
"ដើម្បីជ្រាបជាពត៌មាន និងជួយសហការ"
- មន្ទីរអប់រំយុវជន និងកីឡាខេត្ត-ក្រុង
"ដើម្បីអនុវត្ត"
- សាលារៀនក្រោមឱវាទផ្ទាល់របស់ក្រសួងអប់រំយុវជន និងកីឡា
- កាលប្បវត្តិ
- ឯកសារ_នា.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ៤៣៧ **អយក**.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ អង្គអណ្តែត

ស្ថិតនៅក្នុងឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម ០១៩៦/០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត ០៧៩៦/៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អប.ចចម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកម្រិត១-កម្រិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៤ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សម្រេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « អង្គអណ្តែត » ស្ថិតនៅក្នុងឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ចាប់ពីឆ្នាំសិក្សា ២០០៤-២០០៥ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៤

រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

<u>កន្លែងទទួល</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តតាកែវ "ដើម្បីជាពត៌មាន"
- ដូចប្រការ ៤
- កាលប្បវត្តិ-ឯកសារ នា.មចទ

C:\New school\Lower-New.doc

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការនិងដឹកជញ្ជូន

លេខ ៤៤៤.....ប្រក.សក.បធ

ភ្នំពេញ-ថ្ងៃទី០៥ ខែ០៧ ឆ្នាំ២០០៤

ប្រ កា ស

ស្តីពីការតែងតាំងមន្ត្រី-រាជការ

រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ១៤/អនក្រ.បក ចុះថ្ងៃទី ៣ មិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ៦៤/អនក្រ.បក ចុះថ្ងៃទី ៩ កក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់និងគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និង ច្រកទ្វារកំពង់ផែសមុទ្រ នៅ ទូទាំងព្រះរាជាណាចក្រកម្ពុជា

-យោងអនុក្រឹត្យលេខ ៨១អនក្រ ចុះថ្ងៃទី៣០-០៨-៩៩ ស្តីពីតួនាទីភារកិច្ចរបស់ភ្នាក់ងារកម្ពុជានាវាចរ "កាំសាប"

-យោងលិខិតលេខ ៤១៨ កស ចុះថ្ងៃទី ២៣.០៦.២០០៤ របស់ កាំសាប

-យោងតាមការចាំបាច់របស់កាំសាប

ស ម្រេ ច

ប្រការ១: តំណាងកាំសាប ត្រូវបានចាត់ជាមន្ត្រីសំរបសំរួលបែបបទចេញ-ចូលនាវាអន្តរជាតិនៅច្រកក្អមសំណ ។

ប្រការ២: តំណាងកាំសាប មានតួនាទីជំនួសមុខអោយក្រសួង កំពង់ផែ ក្នុងការធ្វើទំនាក់ទំនងជាមួយសមត្ថកិច្ច ដើម្បីធានាបាននូវភាពរលូន និង ប្រសិទ្ធភាព ក្នុងដំណើរចេញ-ចូលរបស់នាវាមានលក្ខណៈជាអន្តរជាតិ ។

ប្រការ៣: តំណាងកាំសាប ត្រូវធ្វើរបាយការណ៍ទៀងទាត់និងជាប្រចាំមកក្រសួង ដែលជាអាណាព្យាបាលជាបន្ទាន់ នូវរាល់បាតុភាពអសកម្មទាំងឡាយដែល កើតមានករណីជាយថាហេតុ ។

ប្រការ៤: នាយកខុទ្ទកាល័យអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល-អង្គភាពពាក់ព័ន្ធនិងអគ្គនាយក "កាំសាប" មានភារកិច្ចចាត់តាំងមន្ត្រីចុះអនុវត្តការងារតាម ខ្លឹមសារប្រកាសនេះអោយមានប្រសិទ្ធភាព ។

ចំលងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី "ជ្រាបជាពត៌មាន"

-ក្រសួងមហាផ្ទៃ -

-សាលាខេត្តកណ្តាល -

-សាលាខេត្តព្រៃវែង -

-កាំសាប -

-កំពង់ផែភ្នំពេញ -

-សមត្ថកិច្ចច្រកទ្វារព្រំដែនក្អមសំណរ "ជ្រាបជាពត៌មាននិងអនុវត្តន៍"

-ឯកសារ- កាលប្បវត្តិ

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ខ្សាំ អ៊ីវតិក